**SPECIAL PROJECTS SERVICES**
**1515 Hughes Way, Long Beach, CA 90810**
**(562) 997-8047 Fax (562) 997-8302**

# កំណត់ហេតុនៃកម្មវិធីប្រជុំ ឌីខាក់

ថ្ងៃព្រហស្បតិ៍ ទី27 ខែតុលា ឆ្នាំ2011

Teacher Resource Center (TRC), បន្ទប់ ABC

## បើកកម្មវិធីប្រជុំ/ស្វាគមន៍

កម្មវិធីប្រជុំ ក្រុមប្រឹក្សាផ្តល់ឱវាទរវាងក្រសួងអប់រំ ឌីស្រ្ទីគ/សហគមន៍ (ឌីខាក់) សំរាប់ថ្ងៃទី27 ខែតុលា ឆ្នាំ2011 ត្រូវបានប្រកាសបើកនៅម៉ោង 9:30 ព្រឹក ដោយអ្នកស្រី Lynnie Paterno, អនុប្រធាន ឌីខាក់, និង អ្នកស្រី Jill LaCasse, សហប្រធាន ឌីខាក់ ។ មានជំនួយបកប្រែជូនមាតាបិតាតាមរយៈប្រើម៉ាស៊ីនស្តាប់នឹងត្រចៀក ដែលផ្តល់ឡើងដោយ បុគ្គលិក ពីរ នាក់មកពីការិយាល័យ Special Projects Services គឺអ្នកស្រី Mari Giannopoulos (ភាសា អេស្ប៉ាញ៉ុល) និង លោក Sam Keo (ភាសា ខ្មែរ) ។

អ្នកសី Lynnie បានពន្យល់អំពីរបៀបចែក និង ប្រើសៀវភៅធំ ឌីខាក់ (DCAC binder) ដូចតទៅ:

- សាលារៀននិមួយៗនឹងបានទទួលសៀវភៅធំមួយក្បាល
- អ្នកតំណាងសាលារៀននឹងរក្សាទុកអំពីពត៌មានថ្មីៗ និង ក្រដាសស្នាមពត៌មានផ្សេងៗនៅភ្ជាប់សៀវភៅធំ
- យកសៀវភៅធំមកជាមួយ នៅពេលមកចូលរួមកម្មវិធីប្រជុំ ឌីខាក់ រៀងរាល់លើក
- សមាជិកផ្សេងៗ រួមទាំងអ្នកតំណាងសាលារៀនផង នឹងទទួលក្រដាសពត៌មានគិបភ្ជាប់គ្នាជាច្រើនសន្លឹកនៅពេលមកចូលរួមកម្មវិធីប្រជុំរៀងរាល់លើក
- សៀវភៅធំនេះ គឺជាទ្រព្យសម្បត្តិរបស់សាលារៀន ។ បើសិនជាអ្នកផ្លាស់សាលារៀន, អ្នកត្រូវយកវាទៅប្រគល់ជូននាយកសាលា ។

អ្នកស្រី Carol Pratt ទទួលស្វាគមន៍អ្នកស្រី Marilyn King ដែលបានត្រឡប់មកធ្វើការវិញ ។ អ្នកស្រី Marilyn King បានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីក្រុមភ្ញៀវចូលរួម ។ យើងទាំងអស់គ្នាពិតជាមានសេចក្តីនឹករលឹកអ្នកស្រីខ្លាំងណាស់ ។

## ទទួលស្គាល់កំណត់ហេតុ

សមាជិកចូលរួមបានចំណាយពេលសំរាប់អានពិនិត្យឡើងវិញ និង កែតម្រូវអំពីកំណត់ហេតុនៃកម្មវិធីប្រជុំកាលពី ថ្ងៃទី19 ខែឧសភា ឆ្នាំ2011 កន្លងមក ដែលបានសរសេរកត់ទុកដោយអ្នកស្រី Jane Kaylor, អ្នកសរសេរកំណត់ហេតុសំរាប់ក្រុម ឌីខាក់ ។ អ្នកស្រី Carolyn Pate, មកពីសាលារៀន Butler, បានលើកដៃទទួលស្គាល់លើកំណត់ហេតុដោយមានអ្នកស្រី Helen Ford, មកពីសាលារៀន Holy Innocents, បានលើកដៃបង្ហាញជាបន្ទាប់ទៅ ។ កំណត់ហេតុនៃកម្មវិធីប្រជុំត្រូវបានទទួលស្គាល់ស្របច្បាប់ ។

## កម្មវិធីបង្ហាញប្រចាំថ្ងៃ

អ្នកស្រី Carol Pratt, បុគ្គលិកផ្តល់ជំនួយផ្នែកគ្រប់គ្រងទូទៅប្រចាំការិយាល័យ Special Projects Services … “អ្វីទៅហៅថា ឌីខាក់?”
តទៅនេះ គឺជាពាក្យសង្ខេប ដែលអ្នកស្រីបានលើកពិគ្រោះ ។ សូមអានបន្ថែមអំពីពត៌មានសរសេរបង្ហាញនៅលើក្រដាស ដែលបានចែកផ្តល់ ។

- មុខងារនៃ ឌីខាក់ គឺជម្រាបមាតាបិតាអំពីពត៌មាន និង ច្បាប់ទាក់ទងក្រសួងអប់រំ ឌីស្រ្ទីគ និង ប្រមូលគោលគំនិតអំពីកិច្ចការផ្សេងៗទាក់ទងការរួមចំណែកពីមាតាបិតា ។
- មុខងារនៃសមាជិក គឺធ្វើជាអ្នកតំណាងឲ្យសាលារៀន ដោយចូលរួមកម្មវិធីប្រជុំ ឌីខាក់ រៀងរាល់ខែ និង នាំយកពត៌មានពីកម្មវិធីប្រជុំទៅចែកជូនមាតាបិតាផ្សេងៗនៅតាមសាលា រៀនរបស់ពួកគេម្នាក់ៗ ។ *** អ្វីត្រូវធ្វើ: ចូលរួមចំណែកជាមួយ ក្រុមប្រឹក្សាប្រចាំសាលារៀន *** អ្វីអាចធ្វើបាន: ចូលរួមចំណែកជាមួយ អ៊ីឡាក់ និង ក្រុមប្រឹក្សាផ្តល់ឱវាទផ្សេងៗ, តាំងបង្ហាញពត៌មានសំរាប់រាយផ្សាយជូនមាតាបិតា ឬ នៅតាមកម្មវិធីប្រជុំ ភីធីអេ ឬ កម្មវិធីប្រជុំផ្សេងៗសំរាប់មាតាបិតា ។
- យូរៗម្តង គឺយើងមានការសុំឆែកពិនិត្យពីរដ្ឋាពិបាល ។ គេនឹងមកពិនិត្យយើងនៅខែកុម្ភៈ ដោយសើរើមើល ប្រាំពីរ ចំណុច, រាប់ទាំង Title I ផង ដែលយកមកប្រើសំរាប់រៀបចំកម្មវិធី ឌីខាក់ ។
- ខែទីដប់ពីរ គឺគ្មានកម្មវិធីប្រជុំទេ ។ ការរៀបចំកម្មវិធីរបស់យើង គឺសំអាងលើការស្ទង់មតិពីឆ្នាំកន្លងមក និង ច្បាប់តម្រូវនៃ Title I ។
- សាលារៀនទាំងអស់បានចូលរួម ឬ នឹងចូលរួមកម្មវិធីហ្វឹកហ្វឺនផ្នែកសន្តិសុខ ។ នៅកម្មវិធីហ្វឹកហ្វឺននេះ គឺនឹងមានមេរៀនថ្មីសំរាប់បង្ហាញ ដែលនាយកសាលានឹងយកទៅបង្ហាត់សិស្សនៅតាមសាលារៀនអំពីរបៀបគោរពតាមវិន័យ និង រក្សាសេចក្តីគោរពដាក់គ្នាទៅវិញទៅមក ។

អ្នកស្រី Carol Pratt, ជំនួសលោក Robert Williams, នាយកគ្រប់គ្រង Special Projects Services … “ការបង្រួមគម្រោងការណ៍តែមួយសំរាប់ភាពលូតលាស់ផ្នែកសិក្សានៃសិស្សទៅជាមួយគម្រោងការណ៍ LEA”

- ក្រសួងសិក្សាប្រចាំតំបន់ទាំងអស់ ដែលហៅថា Local Educational Agency (LEA) មានមុខងាររៀបចំគម្រោងការណ៍ ដើម្បីបង្កើនភាពលូតលាស់ផ្នែកសិក្សាសំរាប់សិស្ស ។ គណកម្មាធិការ និង អគ្គនាយកធ្វើការសម្រេចរួមគ្នា ដោយសំអាងលើលទ្ធផលផ្នែកប្រឡង តែស្ត ដែលសិស្សបានធ្វើ និង សេចក្តីត្រូវការផ្សេងៗ ។
- ការរៀបចំប្រើថវិកា គឺសំអាងលើអ្វី ដែលត្រូវការដោះស្រាយមុនគេ និង ចំនួនថវិកា ដែលបានទទួលមកពីរដ្ឋាភិបាល រដ្ឋ និង សហព័ន្ធ ។
- គោលដៅរបស់សាលារៀន និង របៀបប្រើថវិកានៅតាមសាលារៀន គឺស្របតាមគម្រោងការណ៍ចាត់ចែងរបស់ក្រសួងអប់រំ ឱ្យស្រ្តីគ និង គម្រោងការណ៍ LEA ហើយបានសរសេរបញ្ចាក់នៅតាម គម្រោងការណ៍តែមួយសំរាប់ភាពលូតលាស់ផ្នែកសិក្សានៃសិស្ស - Single Plan for Student Achievement (SPSA) ។ ក្រុមប្រឹកាប្រចាំសាលារៀន នៅតាមសាលារៀននិមួយៗ នឹងកែសម្រួល រួមទាំងទទួលស្គាល់ចំពោះ គម្រោងការណ៍ SPSA រៀងរាល់ឆ្នាំ ដោយសំអាងលើពត៍មានច្រើនមុខ ។
- អ្នកស្រី Carol Pratt ស្នើសុំគោលគំនិត និង ចង់ដឹងថា តើមានសំនួរអ្វីទេ ។ មានការស្នើសុំឲ្យតាំងបង្ហាញ គម្រោងការណ៍ LEA នៅតាម “វឹបសៃ” ក្រសួងអប់រំ ឱ្យស្រ្តីគ ។ គម្រោងការណ៍ទាំង ពីរ មុខ គឺមានតាំងបង្ហាញហើយ ដែលអាចបើកមើលនៅតាមៈ lbschools.net ។

## សំនួរឆ្លងឆ្លើយ/ការផ្តល់គោលគំនិត

ពាក្យផ្តាំផ្ញើ និង សំនួរផ្សេងៗ គឺអាចសរសេរបង្ហាញបាននៅលើក្រដាសតាម តុ ។ សូមសរសេរបំពេញ ហើយយើងនឹងឆ្លើយតបជូនវិញនៅកម្មវិធីប្រជុំលើកក្រោយ ។

## ថ្លែងប្រកាស

អ្នកស្រី Jill Lacasse, សហប្រធាន, បានពន្យល់ថា មុខតំណែងរបស់អ្នកស្រីជា សហប្រធាន ឱ្យខាក់ ត្រូវបានបញ្ចប់ហើយ ។ ការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅកម្មវិធីប្រជុំលើកក្រោយ ។ បើសិនជាអ្នកមានបំណងកាន់កាប់មុខតំណែងនេះ គឺអ្នកអាចអានសំគាល់ទុកបានអំពីច្បាប់ចែងតម្រូវ និង មុខងារទទួលធ្វើតាម ដែលស្ថិតនៅក្រោម លក្ខន្តិកៈ ។ ចំពោះសមាជិកទាំងអស់ ដែលមានបំណងតែងតាំងឈ្មោះធ្វើជា សហប្រធាន គឺសូមទូរស័ព្ទ ឬ អ៊ីម៉ែល ទាក់ទងអ្នកស្រី Marilyn King ដើម្បីឲ្យគាត់ឆែកមើលអំពីសមត្ថភាពរបស់អ្នក, ក្រោមច្បាប់ចែងតម្រូវ ។ ការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅកម្មវិធីប្រជុំ ឱ្យខាក់ លើកក្រោយ ។

អ្នកស្រី Jill Lacasse បានណែនាំបង្ហាញកម្មិកសមាជិកសព្វថ្ងៃ និង ពន្យល់ថា ពួកគេនឹងកាន់មុខងារបន្តនៅក្រុម ឱ្យខាក់ ជាតំណែងលើកទីពីរ ដែលមានចំនួនពេល ពីរ ឆ្នាំ ។ ជាធម្មតា, គណៈកម្មាធិការ ឱ្យខាក់ ជួបជុំគ្នានៅ ថ្ងៃព្រហស្បតិ៍ មុននឹងដល់ពេលកម្មវិធីប្រជុំ ឱ្យខាក់ ធម្មតាចាប់ផ្តើមឡើង, ពីម៉ោង 9:30–11:00 ព្រឹក, នៅការិយាល័យចាត់ការទូទៅរបស់ក្រសួងអប់រំ ឱ្យស្រ្តីគ ។ អ្នកស្រី Marilyn នឹងទាក់ទងតាមរយៈ អ៊ីម៉ែល ដើម្បីរំលឹកអំពីកម្មវិធីប្រជុំ ។

## បិទបញ្ចប់កម្មវិធី

អ្នកស្រី Carol Pratt ថ្លែងអំណរគុណចំពោះសមាជិកទាំងអស់ ដែលបានអញ្ជើញមកចូលរួម និង រំលឹកថា កម្មវិធីប្រជុំលើកក្រោយទៀត គឺ ថ្ងៃព្រហស្បតិ៍ ទី17 ខែវិច្ឆិកា ឆ្នាំ2011, ម៉ោង 9:30–11:30 ព្រឹក, នៅឯ Teacher Resource Center (TRC) ។

ដោយសេចក្តីគោរព,

Jane Kaylor
អ្នកសរសេរកំណត់ហេតុ